# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
# សេចក្តីប្រកាសព័ត៌មាន

## ការប្រកួតជ្រើសរើសបេក្ខជនចូលរួមកម្មវិធី JENESYS 2019

លេខ: 43 PR-19/EoJ ថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៩

ស្ថានទូតជប៉ុនមានសេចក្តីសោមនស្សរីករាយជម្រាបជូនថា ស្ថានទូតនឹងរៀបចំការប្រកួតជ្រើសរើសបេក្ខជន ដើម្បីចូលរួមកម្មវិធីផ្លាស់ប្តូរយុវជន JENESYS 2019។

និស្សិតឆ្នាំទី៣ គ្រប់ជំនាញនៃសាកលវិទ្យាល័យទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា អាចដាក់ពាក្យចូលរួមការប្រកួតនេះបាន។ និស្សិត២៤រូប ស្មើនឹង៦ក្រុម នឹងត្រូវជ្រើសរើសនៅវគ្គប្រកួតផ្តាច់ព្រ័ត្រ ដើម្បីចូលរួមកម្មវិធី JENESYS 2019។

បេក្ខជនដែលត្រូវបានជ្រើសរើសចូលរួម វគ្គប្រកួតផ្តាច់ព្រ័ត្រ ត្រូវរៀបចំបទបង្ហាញជាភាសាខ្មែរ ក្រោមប្រធានបទ "**ស្រុកកំណើតខ្ញុំ**" ។

កម្មវិធីលម្អិតមានដូចខាងក្រោម៖

- ចាប់ផ្តើមទទួលពាក្យពីថ្ងៃផ្សាយដំណឹងនេះតទៅ
- ផុតកំណត់ទទួលពាក្យ៖ **ថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៩** នៅស្ថានទូតជប៉ុន
- **ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៩** នឹងប្រកាសលទ្ធផលបេក្ខជនដើម្បីចូលរួមប្រកួតវគ្គផ្តាច់ព្រ័ត្រ នៅលើគេហទំព័រស្ថានទូតជប៉ុន
- ការប្រកួតវគ្គផ្តាច់ព្រ័ត្រ៖ **ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៩ ម៉ោង២រសៀល នៅ CJCC**
- ទស្សនកិច្ចនៅប្រទេសជប៉ុន ក្រោមកម្មវិធី JENESYS 2019៖ **រយៈពេលមួយសប្តាហ៍នៃដើម ឬ ចុងខែមករា ឆ្នាំ២០២០**

សម្រាប់ព័ត៌មានបន្ថែម សូមអានគោលការណ៍ណែនាំ ( https://www.kh.emb-japan.go.jp/itpr_en/c_000167.html ) ឬ សូមទាក់ទងមកកាន់ផ្នែកវប្បធម៌ និងព័ត៌មាននៃស្ថានទូតជប៉ុន តាមរយៈទូរស័ព្ទលេខ ០២៣ ២១៧ ១៦១ (១១២២) ឬ info.jpn@pp.mofa.go.jp ។